ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ:ជជ.ន.....សហវ.ប្រ.ភាគ

ប្រកាសអន្តរក្រសួង
ស្តីពី
ការផ្តល់សេវាសាធារណៈរបស់ក្រសួងរ៉ែ និងថាមពល

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៩ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម មាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ

ផ្លូវលេខ ៤២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញព្រះរាជក្រម នស/រកម/០២០១/០៣ ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៥/០០៥ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ១៧៧ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត ផ្នែកដោនស្ទ្រីម
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជ្ញាប័ណ្ណស្វែងរករកនិងអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ១៩៥ អនក្រ.បក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងការនាំចេញផលិតផលរ៉ែ
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់
- បានឃើញអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីគោលការណ៍និងនីតិវិធីបន្ថែមសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធក្នុងក្របខ័ណ្ឌនៃការផ្ទេរមុខងារ និងការចែករំលែកចំណូលមិនមែនសារពើពន្ធ ពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញសារាចរណែនាំលេខ០៧ សរណន ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០ របស់រាជរដ្ឋាភិបាល ស្តីពីវិធានការគ្រប់គ្រងអាជីវកម្មចែកចាយផលិតផលតេលសិលា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

ប្រការ១ .-

សេវាសាធារណៈដែលផ្តល់ដោយក្រសួងរ៉ែ និងថាមពល ត្រូវបានរៀបចំជាកម្រងសេវាសាធារណៈ ដែលមានរាយលម្អិតអំពីប្រភេទសេវា តម្លៃសេវា រយៈពេលអតិបរមានៃការផ្តល់សេវា និងសុពលភាពនៃសេវា ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ ដែលភ្ជាប់នឹងប្រកាសអន្តរក្រសួងនេះ។
ឧបសម្ព័ន្ធទី១ : ជាកម្រងសេវាសាធារណៈ ដែលស្ថិតក្នុងភារកិច្ចរបស់អង្គភាពរដ្ឋបាលកណ្តាលនៃក្រសួងរ៉ែ និងថាមពល។
ឧបសម្ព័ន្ធទី២ : ជាកម្រងសេវាសាធារណៈ ដែលក្រសួងរ៉ែ និងថាមពលធ្វើប្រតិភូកម្មមុខងារជូនរដ្ឋបាលរាជធានី ខេត្ត។

ប្រការ២ .-

ទម្រង់ បែបបទ នីតិវិធី និងលក្ខខណ្ឌនៃការផ្តល់សេវាសាធារណៈទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ត្រូវអនុវត្តតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល។

ប្រការ៣ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៤ .-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ទី ខែ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៤

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

កែវ រតនៈ

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ.ជ.ស.ន.... សហវ.ប្រក.អទច ចុះថ្ងៃទី.ជ.ផ. ខែ.ភក្កដ ឆ្នាំ២០២៤ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរ៉ែ និងថាមពល

កម្រងសេវាសាធារណៈ ដែលស្ថិតក្នុងសាខាកិច្ចរបស់អង្គភាពរដ្ឋបាលកណ្តាលនៃក្រសួងរ៉ែ និងថាមពល

លេខរៀងសេវា		បរិយាយ	តម្លៃឯកតានៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
	I-	**អគ្គនាយកដ្ឋានធនធានរ៉ែ**			
		ក. ការពិនិត្យ ទទួល និងដំណើរការឯកសារ			
១	១	ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំលិខិតបញ្ជាក់ ឬលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ ឬពន្យារបន្ត ឬបន្តសុពលភាព ឬកែប្រែ ឬផ្ទេរសិទ្ធិអាជ្ញាបណ្ណធនធានរ៉ែ	១ ០០០ ០០០	១០ថ្ងៃ	
		ខ. ការចេញលិខិតអនុញ្ញាត ឬការផ្តល់អាជ្ញាបណ្ណ			
២	១	អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ សម្រាប់អាជីវកម្មថ្មសំណង់ ទំហំមិនលើសពី ១ហិកតា និងជម្រៅមិនហួសពី ៥ម៉ែត្រ	១ ០០០ ០០០	៣០ថ្ងៃ	១ឆ្នាំ
៣	២	លិខិតអនុញ្ញាតបុរេសនា	៨ ០០០ ០០០	៣០ថ្ងៃ	៦ខែ
៤	៣	អាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់គោលបំណងអនុវត្តការងារស្វែងរករកថ្មសំណង់ ថ្មអារ ម្ចាងសិលា និងធនធានរ៉ែផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល	១០ ០០០ ០០០	៣០ថ្ងៃ	១ឆ្នាំ
៥	៤	អាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ធ្វើអាជីវកម្មខ្សាច់ ក្រួស អាចម៍ដី ឡាតេរីត ដីឥដ្ឋ មានទំហំមិនលើសពី ១០ហិកតា (ក្នុងករណីទំហំលើសពី ១០ហិកតា ត្រូវបង់បន្ថែមនូវទំហំដែលលើស ដោយផ្អែកលើមូលដ្ឋានគិត ៤០០ ០០០រៀល ក្នុង ១ហិកតា)	១០ ០០០ ០០០	៤៥ថ្ងៃ	២ឆ្នាំ
៦	៥	អាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ធ្វើអាជីវកម្មថ្មសំណង់ ថ្មអារ ម្ចាងសិលា និងធនធានរ៉ែផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល មានទំហំមិនលើសពី ១ហិកតា (ក្នុងករណីទំហំលើសពី ១០ហិកតា ត្រូវបង់បន្ថែមនូវទំហំដែលលើស ដោយផ្អែកលើមូលដ្ឋានគិត ៤០០ ០០០រៀល ក្នុង ១ហិកតា)	២០ ០០០ ០០០	៤៥ថ្ងៃ	២ឆ្នាំ

លេខរៀងសេវា		បរិយាយ	តម្លៃឯកតានៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
៧	៦	អាជ្ញាបណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ទ្រង់ទ្រាយតូច	១ ០០០ ០០០	៤៥ថ្ងៃ	១ឆ្នាំ
៨	៧	អាជ្ញាបណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ទ្រង់ទ្រាយធំ	១៥ ០០០ ០០០	៤៥ថ្ងៃ	២ឆ្នាំ
៩	៨	អាជ្ញាបណ្ណកែច្នៃធនធានរ៉ែ ប្រើកម្លាំងពលកម្មតិចជាង ៧នាក់	៣ ៦០០ ០០០	៤៥ថ្ងៃ	៣ឆ្នាំ
១០	៩	អាជ្ញាបណ្ណកែច្នៃធនធានរ៉ែ ប្រើកម្លាំងពលកម្មចាប់ពី ៧នាក់ ទៅ ១៤នាក់	៧ ២០០ ០០០	៤៥ថ្ងៃ	៣ឆ្នាំ
១១	១០	អាជ្ញាបណ្ណកែច្នៃធនធានរ៉ែ ប្រើកម្លាំងពលកម្មលើសពី ១៤នាក់	១៥ ០០០ ០០០	៤៥ថ្ងៃ	៣ឆ្នាំ
១២	១១	អាជ្ញាបណ្ណស្វែងរុករក	៣០ ០០០ ០០០	៤៥ថ្ងៃ	៣ឆ្នាំ
១៣	១២	អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយតូច	១ ០០០ ០០០	៤៥ថ្ងៃ	១ឆ្នាំ
១៤	១៣	អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយមធ្យម	៣០ ០០០ ០០០	៤៥ថ្ងៃ	៣ឆ្នាំ
១៥	១៤	អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយធំ (គិតក្នុងមួយឆ្នាំ)	១០ ០០០ ០០០	៤៥ថ្ងៃ	មិនលើស ២១ឆ្នាំ
	គ. ការពន្យារសុពលភាពលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ				
១៦	១	លិខិតអនុញ្ញាតបុរេសនា	៤ ០០០ ០០០	៣០ថ្ងៃ	៣ខែ
១៧	២	អាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់គោលបំណងអនុវត្តការងារស្វែងរុករកថ្មសំណង់ ថ្មអារ ម្នាងសិលា និងធនធានរ៉ែផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល	១០ ០០០ ០០០	៣០ថ្ងៃ	១ឆ្នាំ
១៨	៣	អាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ធ្វើអាជីវកម្មខ្សាច់ ក្រួស អាចម៍ដី ឡាតេរីត ដីឥដ្ឋ មានទំហំមិនលើសពី ១០ហិកតា (ក្នុងករណីទំហំលើសពី ១០ហិកតា ត្រូវបង់បន្ថែមនូវទំហំដែលលើស ដោយផ្អែកលើមូលដ្ឋានគិត ៤០០ ០០០រៀល ក្នុង ១ហិកតា)	១០ ០០០ ០០០	៤៥ថ្ងៃ	២ឆ្នាំ
១៩	៤	អាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ធ្វើអាជីវកម្មថ្មសំណង់ ថ្មអារ ម្នាងសិលា និងធនធានរ៉ែផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល មានទំហំមិនលើសពី ១០ហិកតា (ក្នុងករណីទំហំលើសពី ១០ហិកតា ត្រូវបង់បន្ថែមនូវទំហំដែលលើស ដោយផ្អែកលើមូលដ្ឋានគិត ៤០០ ០០០រៀល ក្នុង ១ហិកតា)	២០ ០០០ ០០០	៤៥ថ្ងៃ	២ឆ្នាំ

លេខរៀងសេវា		បរិយាយ	តម្លៃឯកតានៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
២០	៥	អាជ្ញាបណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ទ្រង់ទ្រាយធំ	១៥ ០០០ ០០០	៤៥ថ្ងៃ	២ឆ្នាំ
២១	៦	អាជ្ញាបណ្ណស្វែងរករក	២០ ០០០ ០០០	៤៥ថ្ងៃ	២ឆ្នាំ
២២	៧	អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយតូច	១ ០០០ ០០០	៤៥ថ្ងៃ	១ឆ្នាំ
២៣	៨	អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយមធ្យម	៣០ ០០០ ០០០	៤៥ថ្ងៃ	៣ឆ្នាំ
២៤	៩	អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយធំ (គិតក្នុងមួយឆ្នាំ)	១០ ០០០ ០០០	៤៥ថ្ងៃ	មិនលើស ១០ឆ្នាំ
	ឃ. ការផ្ទេរសិទ្ធិនៃអាជ្ញាបណ្ណធនធានរ៉ែ				
២៥	១	អាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់គោលបំណងអនុវត្តការងារស្វែងរករកថ្មសំណង់ ថ្មអារ ម្នាងសិលា និងធនធានរ៉ែផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល	១០ ០០០ ០០០	៣០ថ្ងៃ	
២៦	២	អាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ធ្វើអាជីវកម្មខ្សាច់ ក្រួស អាចម៍ដី ឡាតេរីត ដីឥដ្ឋ	១០ ០០០ ០០០	៤៥ថ្ងៃ	
២៧	៣	អាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ធ្វើអាជីវកម្មថ្មសំណង់ ថ្មអារ ម្នាងសិលា និងធនធានរ៉ែផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល	៥០ ០០០ ០០០	៤៥ថ្ងៃ	
២៨	៤	អាជ្ញាបណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ទ្រង់ទ្រាយធំ	៥០ ០០០ ០០០	៤៥ថ្ងៃ	
២៩	៥	អាជ្ញាបណ្ណកែច្នៃធនធានរ៉ែ ប្រើកម្លាំងពលកម្មតិចជាង ៧នាក់	២ ៥០០ ០០០	៤៥ថ្ងៃ	
៣០	៦	អាជ្ញាបណ្ណកែច្នៃធនធានរ៉ែ ប្រើកម្លាំងពលកម្មចាប់ពី ៧នាក់ ទៅ ១៤នាក់	៥ ០០០ ០០០	៤៥ថ្ងៃ	
៣១	៧	អាជ្ញាបណ្ណកែច្នៃធនធានរ៉ែ ប្រើកម្លាំងពលកម្មលើសពី ១៤នាក់	៨ ០០០ ០០០	៤៥ថ្ងៃ	
៣២	៨	អាជ្ញាបណ្ណស្វែងរករក	១០០ ០០០ ០០០	៤៥ថ្ងៃ	
៣៣	៩	អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយមធ្យម	១០០ ០០០ ០០០	៤៥ថ្ងៃ	
៣៤	១០	អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយធំ	២០០ ០០០ ០០០	៤៥ថ្ងៃ	

លេខរៀងសេវា		បរិយាយ	តម្លៃឯកតានៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
	ង. ការកែប្រែ (ការចេញលិខិតទទួលស្គាល់ការផ្លាស់ប្តូរសមាសភាពភាគហ៊ុន ឬ/និងការផ្លាស់ប្តូរអ្នកគ្រប់គ្រងក្រុមហ៊ុន, ការរំកិល ឬបន្ថែម ឬបន្ថយផ្នែកដី និងកម្មវត្ថុអាជីវកម្ម) ដែលនាំឱ្យមានការកែប្រែផលប្រយោជន៍ពាក់ព័ន្ធនឹងអាជ្ញាបណ្ណ				
៣៥	១	អាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់គោលបំណងអនុវត្តការងារស្វែងរករកថ្មសំណង់ ថ្មអារ ម្នាងសិលា និងធនធានរ៉ែផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល	៥ ០០០ ០០០	៣០ថ្ងៃ	មិនលើស ១ឆ្នាំ
៣៦	២	អាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ធ្វើអាជីវកម្មខ្សាច់ ក្រួស អាចម៍ដី ឡាតេរីត ជីឥដ្ឋ	២ ៥០០ ០០០	៣០ថ្ងៃ	
៣៧	៣	អាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ធ្វើអាជីវកម្មថ្មសំណង់ ថ្មអារ ម្នាងសិលា និងធនធានរ៉ែផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល	២០ ០០០ ០០០	៣០ថ្ងៃ	
៣៨	៤	អាជ្ញាបណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ទ្រង់ទ្រាយធំ	២២ ០០០ ០០០	៣០ថ្ងៃ	
៣៩	៥	អាជ្ញាបណ្ណកែច្នៃធនធានរ៉ែ ប្រើកម្លាំងពលកម្មតិចជាង ៧នាក់	១ ០០០ ០០០	៣០ថ្ងៃ	
៤០	៦	អាជ្ញាបណ្ណកែច្នៃធនធានរ៉ែ ប្រើកម្លាំងពលកម្មចាប់ពី ៧នាក់ ទៅ ១៤នាក់	២ ០០០ ០០០	៣០ថ្ងៃ	
៤១	៧	អាជ្ញាបណ្ណកែច្នៃធនធានរ៉ែ ប្រើកម្លាំងពលកម្មលើសពី ១៤នាក់	៤ ០០០ ០០០	៣០ថ្ងៃ	
៤២	៨	អាជ្ញាបណ្ណស្វែងរករក	៤៥ ០០០ ០០០	៣០ថ្ងៃ	
៤៣	៩	អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយតូច	១ ០០០ ០០០	៣០ថ្ងៃ	
៤៤	១០	អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយមធ្យម	៥០ ០០០ ០០០	៣០ថ្ងៃ	
៤៥	១១	អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយធំ	១០០ ០០០ ០០០	៣០ថ្ងៃ	
	ច. ការចេញលិខិត ឬវិញ្ញាបនបត្រ បញ្ជាក់ផលិតផលរ៉ែ ឬសំណាករ៉ែ សម្រាប់គោលបំណងនាំចេញ នាំចូល និងបញ្ជាក់បរិមាណរំសេវ-គ្រឿងផ្ទុះនិងសារធាតុគីមី ប្រើប្រាស់ក្នុងការជីកយករ៉ែ				
៤៦	១	ពិនិត្យ និងដំណើរការឯកសារស្នើសុំ លិខិតបញ្ជាក់សំណាករ៉ែ	៥០០ ០០០	៧ថ្ងៃ	៣០ថ្ងៃ
៤៧	២	ពិនិត្យ និងដំណើរការឯកសារស្នើសុំវិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែសម្រាប់ថ្មអារ ម្នាងសិលា និងធនធានរ៉ែផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែល	១ ០០០ ០០០	៧ថ្ងៃ	៣០ថ្ងៃ

លេខរៀងសេវា		បរិយាយ	តម្លៃឯកតានៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
៤៨	៣	ពិនិត្យ និងដំណើរការឯកសារស្នើសុំវិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែសម្រាប់ខ្សាច់ ដីល្បាយខ្សាច់ និងធនធានរ៉ែផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែល	១ ០០០ ០០០	៧ថ្ងៃ	៣០ថ្ងៃ
៤៩	៤	ពិនិត្យ និងដំណើរការឯកសារស្នើសុំវិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែសម្រាប់រ៉ែលោហៈ អលោហៈ និងធនធានរ៉ែផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែល	១ ០០០ ០០០	៧ថ្ងៃ	៣០ថ្ងៃ
៥០	៥	ពិនិត្យ និងដំណើរការឯកសារស្នើសុំវិញ្ញាបនបត្របញ្ជាក់ការនាំចូលផលិតផលរ៉ែ	១ ០០០ ០០០	១៥ថ្ងៃ	៣០ថ្ងៃ
៥១	៦	ពិនិត្យ និងដំណើរការឯកសារស្នើសុំលិខិតកំណត់ភ្ជាប់នាំចេញផលិតផលរ៉ែ (គិតក្នុងមួយភ្ជាប់)	១ ០០០ ០០០	១៥ថ្ងៃ	១ឆ្នាំ
៥២	៧	លិខិតបញ្ជាក់បរិមាណរំសេវ-គ្រឿងផ្ទុះ សម្រាប់អាជីវកម្មធនធានរ៉ែ	៥០០ ០០០	១៥ថ្ងៃ	១ឆ្នាំ
៥៣	៨	លិខិតបញ្ជាក់សារធាតុគីមី សម្រាប់វិស័យរ៉ែ	១ ០០០ ០០០	១៥ថ្ងៃ	
	II- **អគ្គនាយកដ្ឋានប្រេងកាត**				
	ក. ផ្នែកអាប់ស្ទ្រីម				
៥៤	១	ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំចុះកិច្ចព្រមព្រៀងប្រេងកាត	១៦ ៤០០ ០០០	៤៥ថ្ងៃ	
៥៥	២	លិខិតអនុញ្ញាតលើការចរចាកិច្ចព្រមព្រៀងប្រេងកាត	២០៥ ០០០ ០០០	១៨០ថ្ងៃ	
៥៦	៣	ការពន្យារបន្តរយៈពេលលើការចរចាកិច្ចព្រមព្រៀងប្រេងកាត	២០ ៥០០ ០០០	៣០ថ្ងៃ	មិនលើស ៦ខែ (អាស្រ័យលើលិខិតអនុញ្ញាត)
៥៧	៤	ការពន្យារបន្តសុពលភាពកិច្ចព្រមព្រៀងប្រេងកាត	៤១០ ០០០ ០០០	១៨០ថ្ងៃ	មិនលើស ១៥ឆ្នាំ (អាស្រ័យលើកិច្ចព្រមព្រៀង)
៥៨	៥	ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំលិខិតអនុញ្ញាតបុរេសនា ចំពោះគម្រោងទ្រង់ទ្រាយតូច	៤ ១០០ ០០០	៣០ថ្ងៃ	១ឆ្នាំ
៥៩	៦	ការពន្យារបន្តសុពលភាពលិខិតអនុញ្ញាតបុរេសនា ចំពោះគម្រោងទ្រង់ទ្រាយតូច	២ ០៥០ ០០០	៣០ថ្ងៃ	៦ខែ
៦០	៧	ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំលិខិតអនុញ្ញាតលើការចរចាកិច្ចព្រមព្រៀងបុរេសនា	១០២ ៥០០ ០០០	៤៥ថ្ងៃ	១ឆ្នាំ

លេខរៀងសេវា		បរិយាយ	តម្លៃឯកតានៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
៦១	៨	ការពន្យារបន្តរយៈពេលលើការចរចាកិច្ចព្រមព្រៀងបុរេសនា	២០ ៥០០ ០០០	៣០ថ្ងៃ	៦ខែ
៦២	៩	ការពន្យារបន្តសុពលភាពកិច្ចព្រមព្រៀងបុរេសនា	២០ ៥០០ ០០០	៣០ថ្ងៃ	២ឆ្នាំ
៦៣	១០	លិខិតអនុញ្ញាតលើលិខិតទទួលស្គាល់ការផ្ទេរសិទ្ធិគ្រប់គ្រង ឬការប្តូរអំណាចគ្រប់គ្រងគម្រោងប្រេងកាត ឬការទទួលស្គាល់ការលក់ភាគហ៊ុន ចេញ ឬចូល	៤១០ ០០០ ០០០	៩០ថ្ងៃ	
៦៤	១១	លិខិតអនុញ្ញាតលើលិខិតទទួលស្គាល់ការផ្លាស់ប្តូរប្រតិបត្តិករដែលទទួលបន្ទុកអនុវត្តកិច្ចព្រមព្រៀងប្រេងកាត	២០ ៥០០ ០០០	១៥ថ្ងៃ	
៦៥	១២	លិខិតអនុញ្ញាតផលិតកម្មប្រេងកាត	៤១០ ០០០ ០០០	១៨០ថ្ងៃ	តាមគម្រោងផលិតកម្ម
៦៦	១៣	លិខិតអនុញ្ញាតផលិតកម្ម ដើម្បីអភិវឌ្ឍន៍ទីផ្សារពាណិជ្ជកម្មឧស្ម័ន	៤១០ ០០០ ០០០	១៨០ថ្ងៃ	៥ឆ្នាំ
៦៧	១៤	ការអនុញ្ញាតបង្កើត និងដំណើរការមូលដ្ឋានផ្គត់ផ្គង់ទំនិញនិងសេវាបម្រើឱ្យប្រតិបត្តិការប្រេងកាត	១០២ ៥០០ ០០០	១៨០ថ្ងៃ	៥ឆ្នាំ
៦៨	១៥	ការបន្តសុពលភាពការអនុញ្ញាតបង្កើត និងដំណើរការមូលដ្ឋានផ្គត់ផ្គង់ទំនិញនិងសេវាបម្រើឱ្យប្រតិបត្តិការប្រេងកាត	៥១ ២៥០ ០០០	៤៥ថ្ងៃ	៥ឆ្នាំ
៦៩	១៦	លិខិតអនុញ្ញាតចូលដំណាក់កាលទី២ ឬដំណាក់កាលទី៣ នៃរយៈពេលស្វែងរករក	៤១ ០០០ ០០០	៣០ថ្ងៃ	២ឆ្នាំ
៧០	១៧	លិខិតអនុញ្ញាតពន្យារពេលបន្ថែម នៃរយៈពេលស្វែងរករក	៨២ ០០០ ០០០	៣០ថ្ងៃ	មិនលើស ៣ឆ្នាំ (អាស្រ័យលើកិច្ចព្រមព្រៀង)
៧១	១៨	លិខិតអនុញ្ញាតកែសម្រួលលើគម្រោងអភិវឌ្ឍប្រេងកាត	៤១ ០០០ ០០០	៤៥ថ្ងៃ	
៧២	១៩	ការអនុញ្ញាតឱ្យពិនិត្យមើលទិន្នន័យប្រេងកាតដែនគោក (គិតក្នុងមួយប្លុក)	២ ០៥០ ០០០	១៤ថ្ងៃ	១ថ្ងៃ
៧៣	២០	ការអនុញ្ញាតឱ្យពិនិត្យមើលទិន្នន័យប្រេងកាតដែនសមុទ្រ (គិតក្នុងមួយប្លុក)	៤១ ០០០ ០០០	១៤ថ្ងៃ	១ថ្ងៃ
៧៤	២១	ការលក់កញ្ចប់ទិន្នន័យប្រេងកាតដែនគោក (គិតក្នុងមួយប្លុក)	២០ ៥០០ ០០០	៣០ថ្ងៃ	
៧៥	២២	ការលក់កញ្ចប់ទិន្នន័យប្រេងកាតដែនសមុទ្រ (គិតក្នុងមួយប្លុក)	៤១០ ០០០ ០០០	៣០ថ្ងៃ	
៧៦	២៣	លិខិតអនុញ្ញាតសម្រាប់រៃអង្គាសទាំងឆ្នេរ នាំចូលសំណាកគំរូប្រេងកាត	២ ០៥០ ០០០	១៥ថ្ងៃ	៣០ថ្ងៃ
៧៧	២៤	ប្រាក់រង្វាន់ចុះហត្ថលេខាកិច្ចព្រមព្រៀងប្រេងកាត (Agreement Signature Bonus)	តាមការព្រមព្រៀង		

លេខរៀងសេវា		បរិយាយ	តម្លៃឯកតានៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
៧៨	២៥	ប្រាក់រង្វាន់នៃការរកឃើញប្រេងកាត ដែលមានលក្ខណៈពាណិជ្ជកម្ម (Commercial Discovery Bonus)	តាមការព្រមព្រៀង		
៧៩	២៦	ប្រាក់រង្វាន់ផលិតកម្មប្រេងកាត (Production Bonus)	តាមការព្រមព្រៀង		
	ខ. ផ្នែកដោនស្ទ្រីម				
	ខ.១ កិច្ចព្រមព្រៀងវិនិយោគផ្នែកដោនស្ទ្រីម				
៨០	១	លិខិតអនុញ្ញាតការចរចាកិច្ចព្រមព្រៀងវិនិយោគផ្នែកដោនស្ទ្រីម	២០០ ០០០ ០០០	៩០ថ្ងៃ	១ឆ្នាំ
៨១	២	លិខិតអនុញ្ញាតការពន្យារបន្តរយៈពេលចរចាកិច្ចព្រមព្រៀងវិនិយោគផ្នែកដោនស្ទ្រីម	៤០ ០០០ ០០០	៣០ថ្ងៃ	៦ខែ
	ខ.២ សកម្មភាពប្រព្រឹត្តកម្ម				
៨២	១	លិខិតអនុញ្ញាត ឬអនុស្សារណៈនៃការយោគយល់គ្នាស្តីពីការសិក្សាសមិទ្ធិលទ្ធភាពសាងសង់រោងចក្រប្រព្រឹត្តកម្ម	២០ ០០០ ០០០	៤៥ថ្ងៃ	២ឆ្នាំ
៨៣	២	វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់សកម្មភាពប្រព្រឹត្តកម្ម ដែលមានសមត្ថភាពផលិតកម្មសរុបចាប់ពី ៥លានលីត្រឡើងទៅ ក្នុងមួយឆ្នាំ	៣០ ០០០ ០០០	៩០ថ្ងៃ	៥ឆ្នាំ
៨៤	៣	វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់សកម្មភាពប្រព្រឹត្តកម្ម ដែលមានសមត្ថភាពផលិតកម្មសរុបតិចជាង ៥លានលីត្រ ក្នុងមួយឆ្នាំ	៤ ០០០ ០០០	៦០ថ្ងៃ	៥ឆ្នាំ
៨៥	៤	ការបន្តសុពលភាពវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់សកម្មភាពប្រព្រឹត្តកម្ម ដែលមានសមត្ថភាពផលិតកម្មចាប់ពី ៥លានលីត្រឡើងទៅ ក្នុងមួយឆ្នាំ	៣០ ០០០ ០០០	៦០ថ្ងៃ	មិនលើស ៤ឆ្នាំ (អាស្រ័យលើអាយុកាលនៃថវបនភណ្ឌ)
៨៦	៥	ការបន្តសុពលភាពវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់សកម្មភាពប្រព្រឹត្តកម្ម ដែលមានសមត្ថភាពផលិតកម្មសរុបតិចជាង ៥លានលីត្រ ក្នុងមួយឆ្នាំ	៤ ០០០ ០០០	៤៥ថ្ងៃ	មិនលើស ៤ឆ្នាំ (អាស្រ័យលើអាយុកាលនៃថវបនភណ្ឌ)
៨៧	៦	អាជ្ញាបណ្ណប្រព្រឹត្តកម្ម ដែលមានសមត្ថភាពផលិតកម្មសរុបចាប់ពី ៥លានលីត្រឡើងទៅ ក្នុងមួយឆ្នាំ	៤០០ ០០០ ០០០	១៨០ថ្ងៃ	១០ឆ្នាំ
៨៨	៧	ការបន្តសុពលភាពអាជ្ញាបណ្ណប្រព្រឹត្តកម្ម ដែលមានសមត្ថភាពផលិតកម្មសរុបចាប់ពី ៥លានលីត្រឡើងទៅ ក្នុងមួយឆ្នាំ	២០០ ០០០ ០០០	៤៥ថ្ងៃ	១០ឆ្នាំ
៨៩	៨	ការផ្ទេរសិទ្ធិអាជ្ញាបណ្ណប្រព្រឹត្តកម្ម ដែលមានសមត្ថភាពផលិតកម្មចាប់ពី ៥លានលីត្រឡើងទៅ ក្នុងមួយឆ្នាំ	២០០ ០០០ ០០០	៤៥ថ្ងៃ	

លេខរៀងសេវា		បរិយាយ	តម្លៃឯកតានៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
	ខ.៣ សកម្មភាពសន្និធិ				
៩០	១	លិខិតអនុញ្ញាត ឬអនុស្សារណៈនៃការយោគយល់គ្នាស្តីពីការសិក្សាសមិទ្ធិលទ្ធភាពបង្កើតមណ្ឌលសន្និធិ	២០ ០០០ ០០០	៤៥ថ្ងៃ	១៨ខែ
	២	វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់សកម្មភាពសន្និធិ ដែលមានបរិមាណស្តុកសរុប			
៩១	-	ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១០លានលីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ៥លានគីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១០លានលីត្រ	២០ ០០០ ០០០	៩០ថ្ងៃ	៥ឆ្នាំ
៩២	-	ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១លានលីត្រ ដល់ ១០លានលីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ៥០០ ០០០គីឡូក្រាម ដល់ ៥លានគីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១លានលីត្រ ដល់ ១០លានលីត្រ	១០ ០០០ ០០០		៥ឆ្នាំ
៩៣	-	ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១៥០ ០០០លីត្រ ដល់ ១លានលីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ៥០ ០០០គីឡូក្រាម ដល់ ៥០០ ០០០គីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១៥០ ០០០លីត្រ ដល់ ១លានលីត្រ	៤ ០០០ ០០០		៣ឆ្នាំ
៩៤	-	ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត (ក្រៅពីប្រេងរំអិលក្នុងកំប៉ុង ឬធុង) ចាប់ពី ២០១លីត្រ ដល់ ១៥០ ០០០លីត្រ ឬចំពោះឧស្ម័នឥន្ធនៈ (ក្រៅពីឧស្ម័នឥន្ធនៈក្នុងកំប៉ុងឬធុង) ចាប់ពី ១០១គីឡូក្រាម ដល់ ៥០ ០០០គីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលចាប់ពី ២០១លីត្រ ដល់ ១៥០ ០០០លីត្រ	១ ០០០ ០០០	៦០ថ្ងៃ	២ឆ្នាំ
	៣	ការបន្តសុពលភាពវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសន្និធិ ដែលមានបរិមាណស្តុកសរុប			
៩៥	-	ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១០លានលីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ៥លានគីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១០លានលីត្រ	២០ ០០០ ០០០	៦០ថ្ងៃ	មិនលើស ៤ឆ្នាំ

លេខរៀងសេវា		បរិយាយ	តម្លៃឯកតានៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
៩៦	-	ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១លានលីត្រ ដល់ ១០លានលីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ៥០០ ០០០គីឡូក្រាម ដល់ ៥លានគីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១លានលីត្រ ដល់ ១០លានលីត្រ	១០ ០០០ ០០០	៦០ថ្ងៃ	មិនលើស ៣ឆ្នាំ
៩៧	-	ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១៥០ ០០០លីត្រ ដល់ ១លានលីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ៥០ ០០០គីឡូក្រាម ដល់ ៥០០ ០០០គីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១៥០ ០០០លីត្រ ដល់ ១លានលីត្រ	៤ ០០០ ០០០		មិនលើស ៣ឆ្នាំ
៩៨	-	ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត (ក្រៅពីប្រេងរំអិលក្នុងកំប៉ុង ឬធុង) ចាប់ពី ២០១លីត្រ ដល់ ១៥០ ០០០លីត្រ ឬចំពោះឧស្ម័នឥន្ធនៈ (ក្រៅពីឧស្ម័នឥន្ធនៈក្នុងកំប៉ុងឬធុង) ចាប់ពី ១០១គីឡូក្រាម ដល់ ៥០ ០០០គីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលចាប់ពី ២០១លីត្រ ដល់ ១៥០ ០០០លីត្រ	១ ០០០ ០០០		២ឆ្នាំ
	៤	អាជ្ញាបណ្ណសន្និធិ ដែលមានបរិមាណសុកសរុប			
៩៩	-	ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១០លានលីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ៥លានគីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១០លានលីត្រ	៨០ ០០០ ០០០	៩០ថ្ងៃ	១០ឆ្នាំ
១០០	-	ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១លានលីត្រ ដល់ ១០លានលីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ៥០០ ០០០គីឡូក្រាម ដល់ ៥លានគីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១លានលីត្រ ដល់ ១០លានលីត្រ	២០ ០០០ ០០០		
១០១	-	ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១៥០ ០០០លីត្រ ដល់ ១លានលីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ៥០ ០០០គីឡូក្រាម ដល់ ៥០០ ០០០គីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១៥០ ០០០លីត្រ ដល់ ១លានលីត្រ	៤ ០០០ ០០០		

លេខរៀងសេវា		បរិយាយ	តម្លៃឯកតានៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
	៥	ការបន្តសុពលភាពអាជ្ញាបណ្ណសន្និធិ ដែលមានបរិមាណស្តុកសរុប			
១០២	-	ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១០លានលីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ៥លានគីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១០លានលីត្រ	៨០ ០០០ ០០០	៦០ថ្ងៃ	១០ឆ្នាំ
១០៣	-	ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១លានលីត្រ ដល់ ១០លានលីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ៥០០ ០០០គីឡូក្រាម ដល់ ៥លានគីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១លានលីត្រ ដល់ ១០លានលីត្រ	២០ ០០០ ០០០		
១០៤	-	ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១៥០ ០០០លីត្រ ដល់ ១លានលីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ៥០ ០០០គីឡូក្រាម ដល់ ៥០០ ០០០គីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១៥០ ០០០លីត្រ ដល់ ១លានលីត្រ	៤ ០០០ ០០០		
	៦	ការផ្ទេរសិទ្ធិនៃអាជ្ញាបណ្ណសន្និធិ ដែលមានបរិមាណស្តុកសរុប			
១០៥	-	ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១០លានលីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ៥លានគីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១០លានលីត្រ	៤០ ០០០ ០០០	៤៥ថ្ងៃ	
១០៦	-	ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១លានលីត្រ ដល់ ១០លានលីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ៥០០ ០០០គីឡូក្រាម ដល់ ៥លានគីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១លានលីត្រ ដល់ ១០លានលីត្រ	១០ ០០០ ០០០		
១០៧	-	ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១៥០ ០០០លីត្រ ដល់ ១លានលីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ៥០ ០០០គីឡូក្រាម ដល់ ៥០០ ០០០គីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១៥០ ០០០លីត្រ ដល់ ១លានលីត្រ	២ ០០០ ០០០		

លេខរៀងសេវា		បរិយាយ	តម្លៃឯកតានៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
	ខ.៤ សកម្មភាពដឹកជញ្ជូន				
១០៨	១	លិខិតអនុញ្ញាត ឬអនុស្សារណៈនៃការយោគយល់គ្នាស្តីពីការសិក្សាលទ្ធភាពសាងសង់បំពង់បង្ហូរ	២០ ០០០ ០០០	៤៥ថ្ងៃ	២ឆ្នាំ
១០៩	២	វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព សម្រាប់ការដឹកជញ្ជូនតាមបំពង់បង្ហូរ	២០ ០០០ ០០០	៩០ថ្ងៃ	៥ឆ្នាំ
	៣	វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់ការដឹកជញ្ជូនក្រៅពីបំពង់បង្ហូរ ដែលមានមធ្យោបាយដឹកជញ្ជូនមានសមត្ថភាពផ្ទុក			
១១០	-	ចំពោះប្រេងឥន្ធនៈ លើសពី ៣ ០០០លីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ១ ៥០០គីឡូក្រាម (គិតក្នុងមួយមធ្យោបាយផ្ទុក)	២០០ ០០០	៤៥ថ្ងៃ	៣ឆ្នាំ
១១១	-	ចំពោះប្រេងឥន្ធនៈ ចាប់ពី ២០១លីត្រ ដល់ ៣ ០០០លីត្រ ឬចំពោះឧស្ម័នឥន្ធនៈ ចាប់ពី ១០១គីឡូក្រាម ដល់ ១ ៥០០គីឡូក្រាម (គិតក្នុងមួយមធ្យោបាយផ្ទុក)	១០០ ០០០		២ឆ្នាំ
១១២	៤	ការបន្តសុពលភាពវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព សម្រាប់ការដឹកជញ្ជូនតាមបំពង់បង្ហូរ	២០ ០០០ ០០០	៦០ថ្ងៃ	៤ឆ្នាំ
	៥	ការបន្តសុពលភាពវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព សម្រាប់ការដឹកជញ្ជូនក្រៅពីបំពង់បង្ហូរដែលមានមធ្យោបាយដឹកជញ្ជូនមានសមត្ថភាពផ្ទុក			
១១៣	-	ចំពោះប្រេងឥន្ធនៈ លើសពី ៣ ០០០លីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ១ ៥០០គីឡូក្រាម (គិតក្នុងមួយមធ្យោបាយផ្ទុក)	២០០ ០០០	៤៥ថ្ងៃ	៣ឆ្នាំ
១១៤	-	ចំពោះប្រេងឥន្ធនៈ ចាប់ពី ២០១លីត្រ ដល់ ៣ ០០០លីត្រ ឬចំពោះឧស្ម័នឥន្ធនៈ ចាប់ពី ១០១គីឡូក្រាម ដល់ ១ ៥០០គីឡូក្រាម (គិតក្នុងមួយមធ្យោបាយផ្ទុក)	១០០ ០០០		២ឆ្នាំ
១១៥	៦	អាជ្ញាបណ្ណដឹកជញ្ជូនតាមបំពង់បង្ហូរ	៣០០ ០០០ ០០០	១៨០ថ្ងៃ	១០ឆ្នាំ
១១៦	៧	អាជ្ញាបណ្ណដឹកជញ្ជូនក្រៅពីបំពង់បង្ហូរ ដែលមានមធ្យោបាយដឹកជញ្ជូនប្រេងកាត តាមផ្លូវគោក ផ្លូវដែក ផ្លូវទឹក ដែលមធ្យោបាយដឹកជញ្ជូនមានសមត្ថភាពផ្ទុក ចំពោះប្រេងឆៅ ចាប់ពី ២០១លីត្រឡើងក្នុងមួយលើក ឬចំពោះឧស្ម័នធម្មជាតិ ចាប់ពី ១០១គីឡូក្រាមឡើងក្នុងមួយលើក	៣០ ០០០ ០០០	៤៥ថ្ងៃ	១០ឆ្នាំ
១១៧	៨	អាជ្ញាបណ្ណដឹកជញ្ជូនក្រៅពីបំពង់បង្ហូរ ដែលមានមធ្យោបាយដឹកជញ្ជូនផលិតផលប្រេងកាត តាមផ្លូវដែក ផ្លូវទឹក ដែលមធ្យោបាយដឹកជញ្ជូនមានសមត្ថភាពផ្ទុក ចំពោះប្រេងឥន្ធនៈ ចាប់ពី ២០១លីត្រឡើងក្នុងមួយលើក ឬចំពោះឧស្ម័នឥន្ធនៈ ចាប់ពី ១០១គីឡូក្រាមឡើងក្នុងមួយលើក	៣០ ០០០ ០០០	៤៥ថ្ងៃ	១០ឆ្នាំ

លេខរៀងសេវា		បរិយាយ	តម្លៃឯកតានៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
១១៨	៩	ការបន្តសុពលភាពអាជ្ញាបណ្ណដឹកជញ្ជូនតាមបំពង់បង្ហូរ	១៥០ ០០០ ០០០	៤៥ថ្ងៃ	១០ឆ្នាំ
១១៩	១០	ការបន្តសុពលភាពអាជ្ញាបណ្ណដឹកជញ្ជូនក្រៅពីបំពង់បង្ហូរ ដែលមានមធ្យោបាយដឹកជញ្ជូនប្រេងកាត តាមផ្លូវគោក ផ្លូវដែក ផ្លូវទឹក ដែលមធ្យោបាយដឹកជញ្ជូនមានសមត្ថភាពផ្ទុក ចំពោះប្រេងឆៅ ចាប់ពី ២០១លីត្រឡើងក្នុងមួយលើក ឬចំពោះឧស្ម័នធម្មជាតិ ចាប់ពី ១០១គីឡូក្រាមឡើងក្នុងមួយលើក	១៥ ០០០ ០០០	៤៥ថ្ងៃ	១០ឆ្នាំ
១២០	១១	ការបន្តសុពលភាពអាជ្ញាបណ្ណដឹកជញ្ជូនក្រៅពីបំពង់បង្ហូរ ដែលមានមធ្យោបាយដឹកជញ្ជូនផលិតផលប្រេងកាត តាមផ្លូវដែក ផ្លូវទឹក ដែលមធ្យោបាយដឹកជញ្ជូនមានសមត្ថភាពផ្ទុក ចំពោះប្រេងឥន្ធនៈ ចាប់ពី ២០១លីត្រឡើងក្នុងមួយលើក ឬចំពោះឧស្ម័នឥន្ធនៈ ចាប់ពី ១០១គីឡូក្រាមឡើងក្នុងមួយលើក	១៥ ០០០ ០០០	៤៥ថ្ងៃ	១០ឆ្នាំ
១២១	១២	ការផ្ទេរសិទ្ធិនៃអាជ្ញាបណ្ណដឹកជញ្ជូនតាមបំពង់បង្ហូរ	១៥០ ០០០ ០០០	៤៥ថ្ងៃ	
១២២	១៣	ការផ្ទេរសិទ្ធិនៃអាជ្ញាបណ្ណដឹកជញ្ជូនក្រៅពីបំពង់បង្ហូរ ដែលមានមធ្យោបាយដឹកជញ្ជូនប្រេងកាត តាមផ្លូវគោក ផ្លូវដែក ផ្លូវទឹក ដែលមធ្យោបាយដឹកជញ្ជូនមានសមត្ថភាពផ្ទុក ចំពោះប្រេងឆៅ ចាប់ពី ២០១លីត្រឡើងក្នុងមួយលើក ឬចំពោះឧស្ម័នធម្មជាតិ ចាប់ពី ១០១គីឡូក្រាមឡើងក្នុងមួយលើក	១៥ ០០០ ០០០	៤៥ថ្ងៃ	
១២៣	១៤	ការផ្ទេរសិទ្ធិនៃអាជ្ញាបណ្ណដឹកជញ្ជូនក្រៅពីបំពង់បង្ហូរ ដែលមានមធ្យោបាយដឹកជញ្ជូនផលិតផលប្រេងកាត តាមផ្លូវដែក ផ្លូវទឹក ដែលមធ្យោបាយដឹកជញ្ជូនមានសមត្ថភាពផ្ទុក ចំពោះប្រេងឥន្ធនៈ ចាប់ពី ២០១លីត្រឡើងក្នុងមួយលើក ឬចំពោះឧស្ម័នឥន្ធនៈ ចាប់ពី ១០១គីឡូក្រាមឡើងក្នុងមួយលើក	១៥ ០០០ ០០០	៤៥ថ្ងៃ	
	ខ.៥ សកម្មភាពពាណិជ្ជកម្ម				
១២៤	១	អាជ្ញាបណ្ណពាណិជ្ជកម្ម សម្រាប់សកម្មភាពនាំចេញ ឬនាំចូលប្រេងកាត ឬផលិតផលប្រេងកាត	៥០ ០០០ ០០០	៤៥ថ្ងៃ	១០ឆ្នាំ
១២៥	២	ការបន្តសុពលភាពអាជ្ញាបណ្ណពាណិជ្ជកម្ម សម្រាប់សកម្មភាពនាំចេញ ឬនាំចូលប្រេងកាត ឬផលិតផលប្រេងកាត	៤០ ០០០ ០០០	៤៥ថ្ងៃ	១០ឆ្នាំ
១២៦	៣	ការផ្ទេរសិទ្ធិនៃអាជ្ញាបណ្ណពាណិជ្ជកម្ម សម្រាប់សកម្មភាពនាំចេញ ឬនាំចូលប្រេងកាត ឬផលិតផលប្រេងកាត	២៥ ០០០ ០០០	៤៥ថ្ងៃ	

លេខរៀងសេវា		បរិយាយ	តម្លៃឯកតានៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
	ខ.៦	សកម្មភាពវេចខ្ចប់			
	១	វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព សម្រាប់សកម្មភាពវេចខ្ចប់ផលិតផលប្រេងកាត និង/ឬឧស្ម័នឥន្ធនៈ ដែលមានសមត្ថភាពវេចខ្ចប់សរុបក្នុងមួយឆ្នាំ			
១២៧	-	ចំពោះប្រេងឥន្ធនៈ ចាប់ពី ១៥០ ០០០លីត្រឡើងទៅ ឬចំពោះឧស្ម័នឥន្ធនៈ ចាប់ពី ៥០ ០០០គីឡូក្រាមឡើងទៅ	៦ ០០០ ០០០	៦០ថ្ងៃ	៤ឆ្នាំ
១២៨	-	ចំពោះប្រេងឥន្ធនៈ តិចជាង ១៥០ ០០០លីត្រ ឬចំពោះឧស្ម័នឥន្ធនៈ តិចជាង ៥០ ០០០គីឡូក្រាម	៣ ០០០ ០០០		៣ឆ្នាំ
	២	ការបន្តសុពលភាពវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព សម្រាប់សកម្មភាពវេចខ្ចប់ផលិតផលប្រេងកាត និង/ឬឧស្ម័នឥន្ធនៈ ដែលមានសមត្ថភាពវេចខ្ចប់សរុបក្នុងមួយឆ្នាំ			
១២៩	-	ចំពោះប្រេងឥន្ធនៈ ចាប់ពី ១៥០ ០០០លីត្រឡើងទៅ ឬចំពោះឧស្ម័នឥន្ធនៈ ចាប់ពី ៥០ ០០០គីឡូក្រាមឡើងទៅ	៦ ០០០ ០០០	៦០ថ្ងៃ	៣ឆ្នាំ
១៣០	-	ចំពោះប្រេងឥន្ធនៈ តិចជាង ១៥០ ០០០លីត្រ ឬចំពោះឧស្ម័នឥន្ធនៈ តិចជាង ៥០ ០០០គីឡូក្រាម	៣ ០០០ ០០០		២ឆ្នាំ
	៣	អាជ្ញាបណ្ណពាណិជ្ជកម្ម សម្រាប់សកម្មភាពវេចខ្ចប់ផលិតផលប្រេងកាត និង/ឬឧស្ម័នឥន្ធនៈ ដែលមានសមត្ថភាពវេចខ្ចប់សរុបក្នុងមួយឆ្នាំ			
១៣១	-	ចំពោះប្រេងឥន្ធនៈ ចាប់ពី ១៥០ ០០០លីត្រឡើងទៅ ឬចំពោះឧស្ម័នឥន្ធនៈ ចាប់ពី ៥០ ០០០គីឡូក្រាមឡើងទៅ	២០ ០០០ ០០០	៤៥ថ្ងៃ	១០ឆ្នាំ
១៣២	-	ចំពោះប្រេងឥន្ធនៈ តិចជាង ១៥០ ០០០លីត្រ ឬចំពោះឧស្ម័នឥន្ធនៈ តិចជាង ៥០ ០០០គីឡូក្រាម	៥ ០០០ ០០០		
	៤	ការបន្តសុពលភាពអាជ្ញាបណ្ណពាណិជ្ជកម្ម សម្រាប់សកម្មភាពវេចខ្ចប់ផលិតផលប្រេងកាត និង/ឬឧស្ម័នឥន្ធនៈ ដែលមានសមត្ថភាពវេចខ្ចប់សរុបក្នុងមួយឆ្នាំ			
១៣៣	-	ចំពោះប្រេងឥន្ធនៈ ចាប់ពី ១៥០ ០០០លីត្រឡើងទៅ ឬចំពោះឧស្ម័នឥន្ធនៈ ចាប់ពី ៥០ ០០០គីឡូក្រាមឡើងទៅ	២០ ០០០ ០០០	៤៥ថ្ងៃ	១០ឆ្នាំ
១៣៤	-	ចំពោះប្រេងឥន្ធនៈ តិចជាង ១៥០ ០០០លីត្រ ឬចំពោះឧស្ម័នឥន្ធនៈ តិចជាង ៥០ ០០០គីឡូក្រាម	៥ ០០០ ០០០		
	៥	ការផ្ទេរសិទ្ធិអាជ្ញាបណ្ណពាណិជ្ជកម្ម សម្រាប់សកម្មភាពវេចខ្ចប់ផលិតផលប្រេងកាត និង/ឬឧស្ម័នឥន្ធនៈ ដែលមានសមត្ថភាពវេចខ្ចប់សរុបក្នុងមួយឆ្នាំ			
១៣៥	-	ចំពោះប្រេងឥន្ធនៈ ចាប់ពី ១៥០ ០០០លីត្រឡើងទៅ ឬចំពោះឧស្ម័នឥន្ធនៈ ចាប់ពី ៥០ ០០០គីឡូក្រាមឡើងទៅ	១០ ០០០ ០០០	៤៥ថ្ងៃ	
១៣៦	-	ចំពោះប្រេងឥន្ធនៈ តិចជាង ១៥០ ០០០លីត្រ ឬចំពោះឧស្ម័នឥន្ធនៈ តិចជាង ៥០ ០០០គីឡូក្រាម	២ ៥០០ ០០០		
	ខ.៧	សកម្មភាពផ្គត់ផ្គង់ និងចែកចាយឧស្ម័នឥន្ធនៈ			
	១	វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព សម្រាប់សកម្មភាពផ្គត់ផ្គង់ និងចែកចាយឧស្ម័នឥន្ធនៈ តាមបណ្តាញបំពង់បង្ហូរ ដែលមានសមត្ថភាពផ្គត់ផ្គង់ និងចែកចាយសរុបក្នុងមួយឆ្នាំ			
១៣៧	-	ចាប់ពី ៥០ ០០០គីឡូក្រាមឡើងទៅ	១០ ០០០ ០០០	៤៥ថ្ងៃ	៤ឆ្នាំ
១៣៨	-	តិចជាង ៥០ ០០០គីឡូក្រាម	៣ ០០០ ០០០		៣ឆ្នាំ

លេខរៀងសេវា		បរិយាយ	តម្លៃឯកតានៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
	២	ការបន្តសុពលភាពវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព សម្រាប់សកម្មភាពផ្គត់ផ្គង់ និងចែកចាយឧស្ម័នឥន្ធនៈ តាមបណ្តាញបំពង់បង្ហូរ ដែលមានសមត្ថភាពផ្គត់ផ្គង់ និងចែកចាយសរុបក្នុងមួយឆ្នាំ			
១៣៩	-	ចាប់ពី ៥០ ០០០គីឡូក្រាមឡើងទៅ	១០ ០០០ ០០០	៤៥ថ្ងៃ	មិនលើស ៣ឆ្នាំ
១៤០	-	តិចជាង ៥០ ០០០គីឡូក្រាម	៣ ០០០ ០០០		២ឆ្នាំ
	៣	អាជ្ញាបណ្ណផ្គត់ផ្គង់ និងចែកចាយឧស្ម័នឥន្ធនៈតាមបណ្តាញបំពង់បង្ហូរ ដែលមានសមត្ថភាពផ្គត់ផ្គង់ និងចែកចាយសរុបក្នុងមួយឆ្នាំ			
១៤១	-	ចាប់ពី ៥០ ០០០គីឡូក្រាមឡើងទៅ	៣០ ០០០ ០០០	៤៥ថ្ងៃ	១០ឆ្នាំ
១៤២	-	តិចជាង ៥០ ០០០គីឡូក្រាម	១០ ០០០ ០០០		
	៤	ការបន្តសុពលភាពអាជ្ញាបណ្ណផ្គត់ផ្គង់ និងចែកចាយឧស្ម័នឥន្ធនៈតាមបណ្តាញបំពង់បង្ហូរ ដែលមានសមត្ថភាពផ្គត់ផ្គង់ និងចែកចាយសរុបក្នុងមួយឆ្នាំ			
១៤៣	-	ចាប់ពី ៥០ ០០០គីឡូក្រាមឡើងទៅ	៣០ ០០០ ០០០	៤៥ថ្ងៃ	១០ឆ្នាំ
១៤៤	-	តិចជាង ៥០ ០០០គីឡូក្រាម	១០ ០០០ ០០០		
	៥	ការផ្ទេរសិទ្ធិនៃអាជ្ញាបណ្ណផ្គត់ផ្គង់ និងចែកចាយឧស្ម័នឥន្ធនៈតាមបណ្តាញបំពង់បង្ហូរ ដែលមានសមត្ថភាពផ្គត់ផ្គង់ និងចែកចាយសរុបក្នុងមួយឆ្នាំ			
១៤៥	-	ចាប់ពី ៥០ ០០០គីឡូក្រាមឡើងទៅ	១៥ ០០០ ០០០	៤៥ថ្ងៃ	
១៤៦	-	តិចជាង ៥០ ០០០គីឡូក្រាម	៥ ០០០ ០០០		
	ខ.៨ ការពិនិត្យ ការផ្តល់ និងការពន្យារបន្តលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រស្ថានីយប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈ				
១៤៧	-	ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់ការបង្កើតស្ថានីយប្រេងឥន្ធនៈ ឬស្ថានីយឧស្ម័នឥន្ធនៈ ឬស្ថានីយរួមប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈ	២ ០០០ ០០០	២៤ថ្ងៃ	២ឆ្នាំ
១៤៨	-	ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំការបន្តសុពលភាពវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពនៃការបង្កើតស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ ឬស្ថានីយរួមប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈ	២ ០០០ ០០០	២៤ថ្ងៃ	២ឆ្នាំ
១៤៩	-	ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំលិខិតអនុញ្ញាតកែសម្រួលស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ ឬស្ថានីយរួមប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈ	២ ០០០ ០០០	២៤ថ្ងៃ	

លេខរៀងសេវា		បរិយាយ	តម្លៃឯកតានៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
១៥០	-	ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំលិខិតអនុញ្ញាតផ្ទេរម្ចាស់ស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ ឬស្ថានីយរួមប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈ	១ ០០០ ០០០	១០ថ្ងៃ	
	ខ.៩ សកម្មភាពពាក់ព័ន្ធផ្នែកដោនស្ត្រីម				
១៥១	-	លិខិតអនុញ្ញាតផ្តល់សេវាគូសបន្លង់បច្ចេកទេសរៀបចំគ្រឿងបង្គុំទឭសម្ភារៈដែលបម្រើឱ្យសកម្មភាពផ្នែកដោនស្ត្រីម	៣ ០០០ ០០០	៣០ថ្ងៃ	អចិន្ត្រៃយ៍
១៥២	-	លិខិតអនុញ្ញាតដុំទឭសម្ភារៈបម្រើឱ្យសកម្មភាពផ្នែកដោនស្ត្រីម	៣ ០០០ ០០០		
១៥៣	-	លិខិតអនុញ្ញាតផ្តល់សេវា ដំឡើង ជួសជុល ឬថែទាំទឭសម្ភារៈបម្រើឱ្យសកម្មភាពផ្នែកដោនស្ត្រីម	៣ ០០០ ០០០		
១៥៤	-	លិខិតអនុញ្ញាតផ្តល់សេវាពិសោធន៍ប្រេងកាត ផលិតផលប្រេងកាត ឬទឭសម្ភារៈបម្រើឱ្យសកម្មភាពផ្នែកដោនស្ត្រីម	៣ ០០០ ០០០	៦០ថ្ងៃ	
	III- **អគ្គនាយកដ្ឋានថាមពល**				
	ក. ការអនុញ្ញាតឱ្យសិក្សាគម្រោងក្នុងវិស័យថាមពល (សម្រាប់ការវិនិយោគឯកជន)				
១៥៥	១	លិខិតអនុញ្ញាត ឬអនុស្សារណៈយោគយល់គ្នា ឱ្យធ្វើការសិក្សាបុរេសមិទ្ធិលទ្ធភាព ឬសមិទ្ធិលទ្ធភាពគម្រោងផលិតកម្មអគ្គិសនីដោយប្រើប្រេងឥន្ធនៈ ធ្យូងថ្ម ឧស្ម័នឥន្ធនៈ ជីវម៉ាស់ ពន្លឺព្រះអាទិត្យ និងថាមពលកកើតឡើងវិញផ្សេងទៀត ដែលមានអានុភាព មិនលើសពី ១០ ០០០គីឡូវ៉ាត់	១០ ០០០ ០០០	៤៥ថ្ងៃ	មិនលើស ២៤ខែ (អាស្រ័យលើទំហំវិនិយោគ)
	២	លិខិតអនុញ្ញាត ឬអនុស្សារណៈយោគយល់គ្នា ឱ្យធ្វើការសិក្សាបុរេសមិទ្ធិលទ្ធភាព ឬសមិទ្ធិលទ្ធភាពគម្រោងផលិតកម្មអគ្គិសនី ដោយប្រើប្រេងឥន្ធនៈ ធ្យូងថ្ម ឧស្ម័នឥន្ធនៈ រ៉ារីអគ្គិសនី ជីវម៉ាស់ ពន្លឺព្រះអាទិត្យ និងថាមពលកកើតឡើងវិញផ្សេងទៀត ដែលមានអានុភាព			
១៥៦	-	លើសពី ១០ ០០០គីឡូវ៉ាត់ ដល់ ៥០ ០០០គីឡូវ៉ាត់	២០ ០០០ ០០០	៤៥ថ្ងៃ	មិនលើស ២៤ខែ (អាស្រ័យលើទំហំវិនិយោគ)
១៥៧	-	លើសពី ៥០ ០០០គីឡូវ៉ាត់ ដល់ ១០០ ០០០គីឡូវ៉ាត់	៣០ ០០០ ០០០		
១៥៨	-	លើសពី ១០០ ០០០គីឡូវ៉ាត់	៥០ ០០០ ០០០		
១៥៩	៣	លិខិតអនុញ្ញាត ឬអនុស្សារណៈយោគយល់គ្នា ឱ្យធ្វើការសិក្សាបុរេសមិទ្ធិលទ្ធភាព ឬសមិទ្ធិលទ្ធភាពគម្រោងខ្សែបញ្ជូន និងចែកចាយថាមពលអគ្គិសនី (គិតក្នុងមួយគីឡូម៉ែត្រ)	២០ ០០០	៤៥ថ្ងៃ	មិនលើស ២៤ខែ (អាស្រ័យលើទំហំវិនិយោគ)

លេខរៀងសេវា		បរិយាយ	តម្លៃឯកតានៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
	ខ. ការអនុញ្ញាតវិនិយោគសម្រាប់ផលិតកម្មអគ្គិសនី (សម្រាប់ការវិនិយោគឯកជន)				
	១	ប្រកាសអនុញ្ញាត និង/ឬចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងវិនិយោគ សម្រាប់ផលិតកម្មអគ្គិសនី ដែលមានអានុភាព			
១៦០	-	មិនលើសពី ១០ ០០០គីឡូវ៉ាត់	២០ ០០០ ០០០	- ៦០ថ្ងៃ សម្រេចត្រឹមក្រសួង - ២០ថ្ងៃ ក្រោយពីទទួលសិទ្ធិប្រទានពីរាជរដ្ឋាភិបាល	ស្របតាមប្រកាស ឬកិច្ចព្រមព្រៀង
១៦១	-	លើសពី ១០ ០០០គីឡូវ៉ាត់ ដល់ ៥០ ០០០គីឡូវ៉ាត់	៤០ ០០០ ០០០		
១៦២	-	លើសពី ៥០ ០០០គីឡូវ៉ាត់ ដល់ ១០០ ០០០គីឡូវ៉ាត់	៦០ ០០០ ០០០		
១៦៣	-	លើសពី ១០០ ០០០គីឡូវ៉ាត់	១៥០ ០០០ ០០០		
	គ. ការអនុញ្ញាតវិនិយោគសម្រាប់បណ្តាញបញ្ជូន និងចែកចាយអគ្គិសនី (សម្រាប់ការវិនិយោគឯកជន)				
១៦៤	១	ប្រកាសអនុញ្ញាតវិនិយោគអគ្គិសនី សម្រាប់បណ្តាញអគ្គិសនីតង់ស្យុងទាប និង/ឬតង់ស្យុងមធ្យម	១ ០០០ ០០០	៤៥ថ្ងៃ	ស្របតាមកិច្ចព្រមព្រៀង
	២	ប្រកាសអនុញ្ញាត និង/ឬចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងវិនិយោគអគ្គិសនី សម្រាប់បណ្តាញអគ្គិសនី តង់ស្យុងខ្ពស់			
១៦៥	-	១១៥គីឡូវ៉ុល (គិតក្នុងមួយគីឡូម៉ែត្រ)	៨០០ ០០០	- ៦០ថ្ងៃ សម្រេចត្រឹមក្រសួង - ២០ថ្ងៃ ក្រោយពីទទួលសិទ្ធិប្រទានពីរាជរដ្ឋាភិបាល	ស្របតាមកិច្ចព្រមព្រៀង
១៦៦	-	២៣០គីឡូវ៉ុល (គិតក្នុងមួយគីឡូម៉ែត្រ)	១ ០០០ ០០០		
១៦៧	-	៥០០គីឡូវ៉ុល (គិតក្នុងមួយគីឡូម៉ែត្រ)	១ ២០០ ០០០		
	ឃ. ការអនុញ្ញាតផ្ទេរសិទ្ធិវិនិយោគសម្រាប់ផលិតកម្ម បណ្តាញបញ្ជូន និងចែកចាយអគ្គិសនី (សម្រាប់ការវិនិយោគឯកជន)				
	១	ប្រកាសអនុញ្ញាតឱ្យផ្ទេរសិទ្ធិការវិនិយោគផលិតកម្មជាមុនពេល សម្រាប់ផលិតកម្មអគ្គិសនី ដែលមានអានុភាព			
១៦៨	-	មិនលើសពី ១០ ០០០គីឡូវ៉ាត់	២០ ០០០ ០០០	២០ថ្ងៃ	ស្របតាមកិច្ចព្រមព្រៀង
១៦៩	-	លើសពី ១០ ០០០គីឡូវ៉ាត់ ដល់ ៥០ ០០០គីឡូវ៉ាត់	៤០ ០០០ ០០០		

លេខរៀងសេវា		បរិយាយ	តម្លៃឯកតានៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
១៧០	-	លើសពី ៥០ ០០០គីឡូវ៉ាត់ ដល់ ១០០ ០០០គីឡូវ៉ាត់	៦០ ០០០ ០០០	២០ថ្ងៃ	ស្របតាមកិច្ចព្រមព្រៀង
១៧១	-	លើសពី ១០០ ០០០គីឡូវ៉ាត់	១៥០ ០០០ ០០០		
១៧២	២	ប្រកាសអនុញ្ញាតឱ្យផ្ទេរសិទ្ធិការិនិយោគខ្សែបញ្ជូនអគ្គិសនី តង់ស្យុងទាប និង/ឬតង់ស្យុងមធ្យម	១ ០០០ ០០០	២០ថ្ងៃ	ស្របតាមកិច្ចព្រមព្រៀង
១៧៣	៣	ប្រកាសអនុញ្ញាតឱ្យផ្ទេរសិទ្ធិការិនិយោគខ្សែបញ្ជូនអគ្គិសនី តង់ស្យុងខ្ពស់ ១១៥គីឡូវ៉ុល ឬ២៣០គីឡូវ៉ុល ឬ៥០០គីឡូវ៉ុល (គិតក្នុងមួយគីឡូម៉ែត្រ)	១ ០០០ ០០០	២០ថ្ងៃ	ស្របតាមកិច្ចព្រមព្រៀង
	ង. លិខិតអនុញ្ញាតនាំចូល និងប្រើប្រាស់សារធាតុវិទ្យុសកម្ម និងប្រភពវិទ្យុសកម្ម				
	១	លិខិតអនុញ្ញាតនាំចូលសារធាតុវិទ្យុសកម្ម និងប្រភពវិទ្យុសកម្ម			
១៧៤	-	នៅក្នុងចំណាត់ថ្នាក់ទី១ និងទី២ នៃឯកសារ IAEA No.RS-G-1.9 - 2005 (គិតក្នុងមួយប្រភព)	៨០០ ០០០	៤៥ថ្ងៃ	២ឆ្នាំ
១៧៥	-	នៅក្នុងចំណាត់ថ្នាក់ទី៣ ដល់ទី៥ នៃឯកសារ IAEA No.RS-G-1.9 - 2005 (គិតក្នុងមួយប្រភព)	៥០០ ០០០		
	២	លិខិតអនុញ្ញាតប្រើប្រាស់សារធាតុវិទ្យុសកម្ម និងប្រភពវិទ្យុសកម្ម			
១៧៦	-	នៅក្នុងចំណាត់ថ្នាក់ទី១ និងទី២ នៃឯកសារ IAEA No.RS-G-1.9 - 2005 (គិតក្នុងមួយប្រភព)	២ ០០០ ០០០	៤៥ថ្ងៃ	២ឆ្នាំ
១៧៧	-	នៅក្នុងចំណាត់ថ្នាក់ទី៣ ដល់ទី៥ នៃឯកសារ IAEA No.RS-G-1.9 - 2005 (គិតក្នុងមួយប្រភព)	១ ៥០០ ០០០		
	៣	ការបន្តសុពលភាពលិខិតអនុញ្ញាតប្រើប្រាស់សារធាតុវិទ្យុសកម្ម និងប្រភពវិទ្យុសកម្ម			
១៧៨	-	នៅក្នុងចំណាត់ថ្នាក់ទី១ និងទី២ នៃឯកសារ IAEA No.RS-G-1.9 - 2005 (គិតក្នុងមួយប្រភព)	១ ៥០០ ០០០	៤៥ថ្ងៃ	២ឆ្នាំ
១៧៩	-	នៅក្នុងចំណាត់ថ្នាក់ទី៣ ដល់ទី៥ នៃឯកសារ IAEA No.RS-G-1.9 - 2005 (គិតក្នុងមួយប្រភព)	១ ០០០ ០០០		
	ច. ការអនុញ្ញាតឱ្យសិក្សា និងវិនិយោគសាងសង់ប្រព័ន្ធ និងកិច្ចប្រតិបត្តិការផលិតថាមពលចំហាយ (សម្រាប់ការវិនិយោគឯកជន)				
១៨០	១	លិខិតអនុញ្ញាតឱ្យធ្វើការសិក្សាប្រព័ន្ធ និងកិច្ចប្រតិបត្តិការផលិតថាមពលចំហាយ	១០ ០០០ ០០០	៤៥ថ្ងៃ	មិនលើស ២៤ខែ (អាស្រ័យលើទំហំគម្រោង)
១៨១	២	ប្រកាសអនុញ្ញាត ឬ/និងចុះកិច្ចព្រមព្រៀងសាងសង់ប្រព័ន្ធ និងកិច្ចប្រតិបត្តិការផលិតថាមពលចំហាយ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន	៤០ ០០០ ០០០		
១៨២	៣	ប្រកាសអនុញ្ញាត ឬ/និងចុះកិច្ចព្រមព្រៀងសាងសង់ប្រព័ន្ធ និងកិច្ចប្រតិបត្តិការផលិត ថាមពលចំហាយ សម្រាប់ការធ្វើសេវាកម្ម	៨០ ០០០ ០០០		

លេខរៀងសេវា		បរិយាយ	តម្លៃឯកតានៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
	ឆ. ការអនុញ្ញាតឱ្យសិក្សា និងវិនិយោគសាងសង់ប្រព័ន្ធ និងកិច្ចប្រតិបត្តិការចែកចាយថាមពលចំហាយ (សម្រាប់ការវិនិយោគឯកជន)				
១៨៣	១	លិខិតអនុញ្ញាតឱ្យធ្វើការសិក្សាប្រព័ន្ធ និងកិច្ចប្រតិបត្តិការចែកចាយថាមពលចំហាយ (គិតក្នុងមួយគីឡូម៉ែត្រ)	៨០០ ០០០	៤៥ថ្ងៃ	មិនលើស២៤ខែ (អាស្រ័យលើទំហំគម្រោង)
១៨៤	២	ប្រកាសអនុញ្ញាត ឬ/និង ចុះកិច្ចព្រមព្រៀងសាងសង់ប្រព័ន្ធ និងកិច្ចប្រតិបត្តិការចែកចាយថាមពលចំហាយ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន (គិតក្នុងមួយគីឡូម៉ែត្រ)	១ ០០០ ០០០		
១៨៥	៣	ប្រកាសអនុញ្ញាត ឬ/និង ចុះកិច្ចព្រមព្រៀងសាងសង់ប្រព័ន្ធ និងកិច្ចប្រតិបត្តិការចែកចាយថាមពលចំហាយ សម្រាប់ការធ្វើសេវាកម្ម (គិតក្នុងមួយគីឡូម៉ែត្រ)	១ ៥០០ ០០០		
	ជ. ការចេញអាជ្ញាបណ្ណផ្តល់សេវាកម្ម ផលិត និងចែកចាយថាមពលចំហាយ (សម្រាប់ការវិនិយោគឯកជន)				
១៨៦	១	អាជ្ញាបណ្ណសេវាកម្មផលិតថាមពលចំហាយ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន	៥០ ០០០ ០០០	៥០ថ្ងៃ	ពី ៥ឆ្នាំ ទៅ ១០ឆ្នាំ (អាស្រ័យលើទំហំគម្រោង)
១៨៧	២	អាជ្ញាបណ្ណសេវាកម្មផលិតថាមពលចំហាយ សម្រាប់ធ្វើសេវាកម្ម	១០០ ០០០ ០០០		
១៨៨	៣	អាជ្ញាបណ្ណសេវាកម្មចែកចាយថាមពលចំហាយ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន (គិតក្នុងមួយគីឡូម៉ែត្រ)	១ ០០០ ០០០		
១៨៩	៤	អាជ្ញាបណ្ណសេវាកម្មចែកចាយថាមពលចំហាយ សម្រាប់ធ្វើសេវាកម្ម (គិតក្នុងមួយគីឡូម៉ែត្រ)	១ ៥០០ ០០០		
	ឈ. ការអនុញ្ញាត ផ្ទេរសិទ្ធិ និង/ឬបន្តអាជ្ញាបណ្ណផ្តល់សេវាកម្ម ផលិតនិងចែកចាយ ថាមពលចំហាយ (សម្រាប់ការវិនិយោគឯកជន)				
១៩០	១	ការផ្ទេរសិទ្ធិ និង/ឬបន្តអាជ្ញាបណ្ណសេវាកម្មផលិតថាមពលចំហាយ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន	៣៥ ០០០ ០០០	៤៥ថ្ងៃ	
១៩១	២	ការផ្ទេរសិទ្ធិ និង/ឬបន្តអាជ្ញាបណ្ណសេវាកម្មផលិតថាមពលចំហាយ សម្រាប់ធ្វើសេវាកម្ម	៧០ ០០០ ០០០		
១៩២	៣	ការផ្ទេរសិទ្ធិ និង/ឬបន្តអាជ្ញាបណ្ណសេវាកម្មចែកចាយថាមពលចំហាយ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន (គិតក្នុងមួយគីឡូម៉ែត្រ)	៧០០ ០០០		
១៩៣	៤	ការផ្ទេរសិទ្ធិ និង/ឬបន្តអាជ្ញាបណ្ណសេវាកម្មចែកចាយថាមពលចំហាយ សម្រាប់ធ្វើសេវាកម្ម (គិតក្នុងមួយគីឡូម៉ែត្រ)	១ ០០០ ០០០		

ឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងលេខ.[illegible]..... សហវ.ប្រក.អទច ចុះថ្ងៃទី[illegible].. ខែ[illegible]. ឆ្នាំ២០២៤ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរ៉ែ និងថាមពល

ក្រមួចសេវាសាធារណៈ ដែលក្រសួងរ៉ែ និងថាមពលធ្វើប្រតិភូកម្មមុខងារជូនរដ្ឋបាលរាជធានី ខេត្ត

លេខរៀងសេវា		បរិយាយ	តម្លៃឯកតានៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
	I- **វិស័យរ៉ែ**				
	ក. សេវាដំណើរការឯកសារស្នើសុំ				
១	១	ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ	១០០ ០០០	១០ថ្ងៃ	
	ខ. ការផ្តល់អាជ្ញាបណ្ណ				
២	១	អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ សម្រាប់អាជីវកម្មជីកយកអាចម៍ដី ដីក្រហម ខ្សាច់ ឬក្រួស ដែលមានផ្ទៃក្រឡាមិនលើសពី ១ហិកតា និងជម្រៅមិនលើសពី ៥ម៉ែត្រ	២០០ ០០០	៣០ថ្ងៃ	១ឆ្នាំ
៣	២	អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ សម្រាប់ការបូមយកខ្សាច់ ដី ល្បាប់ ឬក្រួសតាមផ្លូវទឹក ដែលមានផ្ទៃក្រឡាមិនលើសពី ១ហិកតា	២០០ ០០០	៣០ថ្ងៃ	១ឆ្នាំ
៤	៣	អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ សម្រាប់អាជីវកម្មរ៉ែមាស ក្រោមទម្រង់ជាការដ្ឋានអណ្តូងរ៉ែបើក ដែលមានផ្ទៃក្រឡាមិនលើសពី ១ហិកតា និងជម្រៅមិនលើសពី ៥ម៉ែត្រ	១ ០០០ ០០០	៣០ថ្ងៃ	១ឆ្នាំ
៥	៤	អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ សម្រាប់អាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ពាក់កណ្តាលមានតម្លៃ និងថ្មសំអាង ដែលមានផ្ទៃក្រឡាមិនលើសពី ១ហិកតា និងជម្រៅមិនលើសពី ៥ម៉ែត្រ	១ ៥០០ ០០០	៣០ថ្ងៃ	១ឆ្នាំ
៦	៥	អាជ្ញាបណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ សម្រាប់គោលបំណងអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ពាក់កណ្តាលមានតម្លៃ និងថ្មសំអាង ជាលក្ខណៈខ្នាតតូចក្រោមទម្រង់ជាការដ្ឋានអណ្តូងរ៉ែក្រោមដី ដែលមានផ្ទៃក្រឡាមិនលើសពី ១ហិកតា និងជម្រៅមិនលើសពី ២០ម៉ែត្រ	១ ៥០០ ០០០	៣០ថ្ងៃ	១ឆ្នាំ

លេខរៀងសេវា		បរិយាយ	តម្លៃឯកតានៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
៧	៦	អាជ្ញាបណ្ណខុសប្បាហកម្មអាជីវកម្មធនធានរ៉ែ សម្រាប់អាជីវកម្មរ៉ែមាសជាលក្ខណៈខ្នាតតូចក្រោមទម្រង់ជាការដ្ឋានអណ្តូងរ៉ែក្រោមដី ដែលមានផ្ទៃក្រឡាមិនលើសពី ១ហិកតា និងជម្រៅមិនលើសពី ២០ម៉ែត្រ	១ ៥០០ ០០០	៣០ថ្ងៃ	១ឆ្នាំ
	II- **ទិសស្ថាប្រែឧភាគ**				
៨	១	លិខិតអនុញ្ញាតប្រព្រឹត្តកម្ម ដែលមានសមត្ថភាពផលិតកម្មសរុបតិចជាង ៥លានលីត្រ ក្នុងមួយឆ្នាំ	២ ០០០ ០០០	៦០ថ្ងៃ	អចិន្ត្រៃយ៍
៩	២	ការផ្ទេរសិទ្ធិលិខិតអនុញ្ញាតប្រព្រឹត្តកម្ម ដែលមានសមត្ថភាពផលិតកម្មសរុបតិចជាង ៥លានលីត្រ ក្នុងមួយឆ្នាំ	១ ០០០ ០០០	៤៥ថ្ងៃ	
១០	៣	លិខិតអនុញ្ញាតសម្រាប់សន្និធិ ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត (ក្រៅពីប្រេងរំអិលក្នុងកំប៉ុង ឬធុង) ដែលមានបរិមាណស្តុកចាប់ពី ២០១លីត្រ ដល់ ១៥០ ០០០លីត្រ ឬចំពោះឧស្ម័នឥន្ធនៈ (ក្រៅពីឧស្ម័នឥន្ធនៈក្នុងកំប៉ុង ឬធុង) ដែលមានបរិមាណស្តុកចាប់ពី ១០១គីឡូក្រាម ដល់ ៥០ ០០០គីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម ដែលមានបរិមាណស្តុកសមមូលចាប់ពី ២០១លីត្រ ដល់ ១៥០ ០០០លីត្រ	១ ០០០ ០០០	៦០ថ្ងៃ	អចិន្ត្រៃយ៍
១១	៤	ការផ្ទេរសិទ្ធិនៃលិខិតអនុញ្ញាតសម្រាប់សន្និធិ ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត (ក្រៅពីប្រេងរំអិលក្នុងកំប៉ុង ឬធុង) ដែលមានបរិមាណស្តុកចាប់ពី ២០១លីត្រ ដល់ ១៥០ ០០០លីត្រ ឬចំពោះឧស្ម័នឥន្ធនៈ (ក្រៅពីឧស្ម័នឥន្ធនៈក្នុងកំប៉ុង ឬធុង) ដែលមានបរិមាណស្តុកចាប់ពី ១០១គីឡូក្រាម ដល់ ៥០ ០០០គីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម ដែលមានបរិមាណស្តុកសមមូលចាប់ពី ២០១លីត្រ ដល់ ១៥០ ០០០លីត្រ	៥០០ ០០០	៤៥ថ្ងៃ	
១២	៥	លិខិតអនុញ្ញាតដឹកជញ្ជូនក្រៅពីបំពង់បង្ហូរ ដែលមានមធ្យោបាយដឹកជញ្ជូនផលិតផលប្រេងកាតតាមយានយន្តផ្លូវគោក ដែលមធ្យោបាយដឹកជញ្ជូនមានសមត្ថភាពស្តុក ចំពោះប្រេងឥន្ធនៈ ចាប់ពី ២០១លីត្រឡើងក្នុងមួយលើក ឬចំពោះឧស្ម័នឥន្ធនៈ ចាប់ពី ១០១គីឡូក្រាមឡើង ក្នុងមួយលើក	១ ៥០០ ០០០	៤៥ថ្ងៃ	អចិន្ត្រៃយ៍

លេខរៀងសេវា	បរិយាយ		តម្លៃឯកតានៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
១៣	៦	ការផ្ទេរសិទ្ធិនៃលិខិតអនុញ្ញាតដឹកជញ្ជូនក្រៅពីបំពង់បង្ហូរ ដែលមានមធ្យោបាយដឹកជញ្ជូនផលិតផលប្រេងកាតតាមយានយន្តផ្លូវគោក ដែលមធ្យោបាយដឹកជញ្ជូនមានសមត្ថភាពផ្ទុក ចំពោះប្រេងឥន្ធនៈ ចាប់ពី ២០១លីត្រឡើងក្នុងមួយលើក ឬចំពោះឧស្ម័នឥន្ធនៈ ចាប់ពី ១០១គីឡូក្រាមឡើង ក្នុងមួយលើក	១ ០០០ ០០០	៤៥ថ្ងៃ	
១៤	៧	លិខិតអនុញ្ញាតពាណិជ្ជកម្ម សម្រាប់ស្ថានីយប្រេងឥន្ធនៈ ឬស្ថានីយឧស្ម័នឥន្ធនៈ ឬស្ថានីយរួមប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈ ដែលមានសមត្ថភាពស្តុកចាប់ពី ២០១លីត្រ ដល់ ១៥០ ០០០ លីត្រ ចំពោះប្រេងឥន្ធនៈ និងចាប់ពី ១០១ គីឡូក្រាម ដល់ ៥០ ០០០ គីឡូក្រាម ចំពោះឧស្ម័នឥន្ធនៈ	១ ០០០ ០០០	៤៥ថ្ងៃ	អចិន្ត្រៃយ៍
១៥	៨	ការផ្ទេរសិទ្ធិនៃលិខិតអនុញ្ញាតពាណិជ្ជកម្ម សម្រាប់ស្ថានីយប្រេងឥន្ធនៈ ឬស្ថានីយឧស្ម័នឥន្ធនៈ ឬស្ថានីយរួមប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈ ដែលមានសមត្ថភាពស្តុកចាប់ពី ២០១លីត្រ ដល់ ១៥០ ០០០លីត្រ ចំពោះប្រេងឥន្ធនៈ និងចាប់ពី ១០១គីឡូក្រាម ដល់ ៥០ ០០០គីឡូក្រាម ចំពោះឧស្ម័នឥន្ធនៈ		៥០០ ០០០	៤៥ថ្ងៃ	